# សុវត្ថិភាពចរាចរណ៍

## ច្បាប់ | ផែនការ | ការអនុវត្តន៍

### ច្បាប់ចរាចរណ៍ផ្លូវគោក

ច្បាប់ចរាចរណ៍ថ្មីនេះបានតាក់តែងឡើង ដោយផ្អែកលើហានិភ័យដែលកំពុងប្រឈមនឹងឃាតករទី១ ដែលបានសម្លាប់មនុស្សនៅលើដងផ្លូវជារៀងរាល់ថ្ងៃ។ ច្បាប់នេះត្រូវបានអនុម័តនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ ដែលនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ ហើយច្បាប់នេះបានបង្ហាញពីការរួមចំណែកនូវការចូលរួមមតិយោបល់របស់សង្គមស៊ីវិលទាំងក្នុងដំណើរការតាក់តែង និងគាំទ្រការអនុម័តច្បាប់។ ច្បាប់នេះនឹងជួយដោះស្រាយបញ្ហាចរាចរនៅក្នុងប្រទេសកម្ពុជាដោយហេតុថា ខ្លឹមសារសំខាន់ៗនៅក្នុងច្បាប់ថ្មីមានការគ្របដណ្តប់ទូលំទូលាយជាងច្បាប់ដំបូង(២០០៧) ដូចជាការការពារសុវត្ថិភាពអ្នកធ្វើដំណើរ ដោះស្រាយបញ្ហាធ្វើដំណើរ និងរឹតបន្តឹងចំពោះអ្នកប្រើប្រាស់ផ្លូវថ្នល់។

### អនុក្រឹត្យ

រដ្ឋាភិបាលបានចេញអនុក្រឹត្យចំនួនបីស្តីពី ″ការកំណត់ល្បឿនសម្រាប់យានជំនិះ″ ‶ការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក″ និង‶ការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក″ ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ដែលមានគោលបំណងកំណត់ល្បឿនបើកបរអតិបរមាសម្រាប់យានជំនិះគ្រប់ប្រភេទ បង្ការទប់ស្កាត់បទល្មើសនឹងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក រក្សាសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក និងការពារអាយុជីវិត មនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន។

### គោលនយោបាយ

គណកម្មាធិការជាតិសុវត្ថិភាបចរាចរណ៍ផ្លូវគោកបានរៀបចំគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ដែល
គោលនយោបាយនេះ មានចក្ខុវិស័យកាត់បន្ថយជាអតិបរិមានូវគ្រោះថ្នាក់ចរាចរណ៍ផ្លូវ គោក ដើម្បីបញ្ចៀសនូវការស្លាប់ របួស ពិការភាព ការខូចខាតទ្រព្យសម្បត្តិ និងការប៉ះពាល់បរិស្ថានក្នុងព្រះរាជាណាចក្រកម្ពុជា។



## ផែនការ

គណកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកបានបង្កើតនូវផែនការសកម្មភាពជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ ២០១៥ ដែលមានចក្ខុវិស័យ ដូចគ្នាទៅនឹងគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក។ ផែនការសកម្មភាពនេះមានគោលបំណងរួម គឺគាំទ្រដល់ការអនុវត្តផែនការសកម្មភាពជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០១១-២០២០ ដែលជាឧបសម្ព័ន្ធនៃគោលនយោបាយជាតិ ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលរាជរដ្ឋាភិបាលបានអនុម័តរួចកាលពីថ្ងៃ ទី២១ ខែកុម្ភៈ ឆ្នាំ២០១៤។ ផែនការសកម្មភាពជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកមានគោលដៅចំនួនបីគឺ ១-កាត់បន្ថយចំនួនអ្នកស្លាប់១០%ធៀបនឹងចំនួនអ្នកស្លាប់ក្នុងឆ្នាំ២០១៤ ២-កាត់បន្ថយចំនួនអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកក្នុងចំណោមប្រជាពលរដ្ឋ១០០ ០០០នាក់ ឱ្យបាន១០%ក្នុងឆ្នាំ២០១៥ ៣-កាត់បន្ថយចំនួនអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ក្នុងចំណោមយានយន្ត១០ ០០០គ្រឿងឱ្យបាន១០%ក្នុងឆ្នាំ២០១៥។ ក្រសួងមហាផ្ទៃបានបង្កើតផែនការស្តីពីការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្មី លេខ០៣៥ផក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥។ ក្រសួងមហាផ្ទៃបានដាក់ចេញនូវគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដែលក្នុងនោះក៏បានលើកឡើងអំពីសុវត្ថិភាពចរាចរផ្លូវគោកផងដែរ ម្យ៉ាងទៀតការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកពុំមានចែងជាក់លាក់នៅក្នុងផែនការសកម្មភាព និងថវិកា ទាំងថ្នាក់ខេត្ត និងស្រុក។ គោលនយោបាយភូមិឃុំមានសុវត្ថិភាពរួមមាន ១)លុបបំបាត់អំពើលួចឆក់ប្លន់ ២)គ្មានចរាចរណ៍ចែកចាយគ្រឿងញៀន ៣)គ្មានអំពើអនាចារ និងការជួញដូរស្រ្តីនិងកុមារ៤)គ្មានក្មេងទំនើង និង ជនទំនើង ៥)គ្មានល្បែងស៊ីសង ៦)គ្មានគ្រោះថ្នាក់ចរាចរណ៍ ៧)គ្រោះថ្នាក់ដែលបណ្តាលមកពី អាវុធយុទ្ធភណ្ឌគ្រប់ប្រភេទ ៨)គ្មានការត្រួតពិនិត្យខុសច្បាប់ ‶កុងត្រូលជជុះ″ និង ៩)គ្មានការប្រើប្រាស់ អាវុធខុសច្បាប់។

# អនុសាសន៍

1. ការអនុវត្តន៍ច្បាប់ត្រូវធានាឱ្យបាននូវភាពស្មើភាពគ្នា មិនប្រកាន់បក្សពួក និងមានតម្លាភាព។

2. ផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយពីចំណុចសំខាន់ៗនៃច្បាប់ នីតិវិធីក្នុងការផាកពិន័យនិងតម្លៃ ទោសទណ្ឌ និងផ្លាកសញ្ញាចរាចរណ៍។

3. ពិចារណានិងគិតគូរអោយបានគ្រប់ជ្រុងជ្រោយព្រមទាំងបង្កើតនូវយន្តការច្បាស់លាស់ដែលសមស្របនឹងស្ថានភាពសង្គមបច្ចុប្បន្នដើម្បីធានាបានការចូលរួមពេញលេញរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់មជ្ឈដ្ឋានក្នុងការត្រៀមលក្ខណៈអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្មីនៅថ្ងៃទី០១ខែមករាឆ្នាំ២០១៦។ ការអនុវត្តន៍គួរគប្បីធ្វើការសាកល្បងក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយ និងគួរធ្វើជាជំហានៗ ដែលមិនគួរចាប់ផ្តើមអនុវត្តគ្រប់លក្ខខណ្ឌទាំងអស់ក្នុងពេលតែមួយ។

4. ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ និងអាជ្ញាធរមូលដ្ឋាននានាព្រមទាំងជំរុញអោយមានផែនការច្បាស់លាស់ដល់ថ្នាក់ស្រុកឃុំ និងគាំទ្រដល់ការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋគ្រប់ទិសទី។

5. បន្តនិងលើកកម្ពស់ការពិភាក្សាជាមួយភាគីពាក់ព័ន្ធនានា អំពីច្បាប់ចរាចរណ៍និងការអនុវត្តន៍ និងគោលនយោបាយដើម្បីគ្រប់គ្រងគ្រឿងស្រវឹង។

6. សហការជាមួយដៃគូពាក់ព័ន្ធ និងកៀងគរធនធាន ដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ ចរាចរណ៍ផ្លូវគោកឱ្យមានប្រសិទ្ធិភាព។

៧. បញ្ជ្រាបគោលការណ៍សុវត្ថិភាពចរាចរក្នុងកម្មវិធីសិក្សាគ្រប់កម្រិតតាំងពីបឋមសិក្សាដល់ឧត្តមសិក្សា។

៨. គ្រប់ស្ថាប័នសាធារណៈ ឯកជន និងសង្គមស៊ីវិលគួរមានបញ្ជ្រាបគោលការណ៍សុវត្ថិភាពចរាចរណ៍បឋមក្នុងគោលនយោបាយរបស់ខ្លួនជាពិសេសផ្តោតលើការពាក់មួកសុវត្ថិភាព ការយល់ដឹងផ្លាកសញ្ញានិងការពាក់ខ្សែក្រវាត់សុវត្ថិភាពរាល់ពេលបើកបរ។

៩. កំណត់រយៈពេលច្បាស់លាស់ក្នុងការធ្វើវិសោធនកម្មច្បាប់ក្នុងករណីការអនុវត្តច្បាប់មានកត្តាប្រឈមច្រើនហួសហេតុ និងមិនមានប្រសិទ្ធភាព ដោយមានការចូលរួមមតិយោបល់ពីសង្គមស៊ីវិល និងមជ្ឈដ្ឋានពាក់ព័ន្ធនានាគ្រប់កម្រិត។

១០.ពង្រឹងយន្តការសង្គ្រោះបន្ទាន់ច្បាស់លាស់ ដើម្បីធានាបាននូវភាពរស់រានមានជីវិត និងសុខភាពជនរងគ្រោះ ក្នុងគោលបំណងរួមចំណែកដល់អត្រាស្លាប់ដោយសារគ្រោះថ្នាក់ចរាចរ។

១១.គួរពិចារណានិងចាប់ផ្តើមពិភាក្សាបន្ថែមទៀតលើគោលនបាយធានារ៉ាប់រងដល់គ្រប់យានយន្ត។

# ការអនុវត្តន៍ច្បាប់

នៅប្រទេសកម្ពុជាយ៉ាងហោចណាស់មានមនុស្សចំនួន៦នាក់បានបាត់បង់ជីវិតនិងចំនួន១៧នាក់បានរងរបួសយ៉ាងធ្ងន់ធ្ងរដោយសារគ្រោះថ្នាក់ចរាចរណ៍ជារៀងរាល់ថ្ងៃ។ ចំនួនអ្នកស្លាប់នេះច្រើនជាង៣០ដងនៃចំនួនសរុបនៃការស្លាប់ដោយសារជំងឺគ្រុនចាញ់ គ្រុនឈាម, និងគ្រាប់មីន / UXOs។ ចាប់តាំងពីឆ្នាំ២០១៤ ដល់ឆ្នាំ២១០៥នេះ អត្រានៃការស្លាប់កើនឡើងរហូតដល់៥% - ដែលជាការកើនឡើងជាលំដាប់ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ២០០០មក។ លើសពីនេះទៀតកម្ពុជាបានបាត់បង់ពី២% ទៅ៣% នៃផលិតផលក្នុងស្រុកសរុប(GDP) របស់ខ្លួនជារៀងរាល់ឆ្នាំដោយសារគ្រោះថ្នាក់ចរាចរណ៍។

បច្ចុប្បន្ននេះការអនុវត្តច្បាប់ចរាចរណ៍ហាក់ដូចជាមិនបានពេញលេញឆ្លើយតបនឹងគោលបំណងនៃច្បាប់ចរាចរណ៍ឡើយ ការអនុវត្តន៍យ៉ាងគង្គក់នៅក្នុងត្រីមាសដំបូងនៃឆ្នាំ២០១៦ បានធ្វើឱ្យមានប្រតិកម្ម និងសញ្ញាណទៅធ្វើវិសោធនកម្មច្បាប់នេះ។ ម្យ៉ាងទៀតក្រសួងមហាផ្ទៃបានដាក់ចេញនូវគោលនយោបាយភូមិឃុំមានសុវត្ថិភាពសម្រាប់ថ្នាក់ក្រោមជាតិ ដែលក្នុងនោះក៏បានលើកឡើងអំពីសុវត្ថិភាពចរាចរផ្លូវគោកផងដែរ ម្យ៉ាងទៀតការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកពុំមានចែងដាក់លាក់នៅក្នុងផែនការសកម្មភាព និងថវិកាទាំងថ្នាក់ខេត្ត និងស្រុក។ បញ្ហាប្រឈមក្នុងការអនុវត្តរបស់ក្រុមប្រឹក្សាឃុំគឺការខ្វះធនធានថវិកា និងធនធានមនុស្សគ្រប់គ្រាន់ក្នុងការបំពេញការងារ ចរាចរ សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងឃុំនៅមានកម្រិតនៅឡើយ។

ម្យ៉ាងទៀតក្រុមមន្ត្រីនគរបាលមួយចំនួនអនុវត្តក្រមវិន័យសីលធម៌វិជ្ជាជីវៈមិនទាន់បានពេញលេញ ដែលជាហេតុនាំឲ្យការអនុវត្តន៍ច្បាប់ចរាចរណ៍ប្រព្រឹត្តទៅដោយពុំមានសុវត្ថិភាពយុត្តិធម៌ និងតម្លាភាព (យោងតាមប្រសាសន៍ នាយឧត្តមសេនីយ៍ ជួន សុវណ្ណ អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញកាលពីថ្ងៃទី ១៨ ខែមេសាឆ្នាំ២០១៦) បញ្ហាទាំងនោះរួមមាន ការបង់ប្រាក់ពិន័យមិនមានវិកយប័ត្រ មិនផាកពិន័យចំពោះអ្នកមានមុខងារជាប៉ូលីស ស៊ីសំណូកតាមរយៈការមិនចូលថ្លឹង លួចដោះលែងរថយន្តដឹកលើសទម្ងន់ និងប៉ូលីសជាអ្នកអនុវត្តច្បាប់មិនគោរពច្បាប់ដូចជាការមិនពាក់មួកសុវត្ថិភាពក្នុងពេលធ្វើដំណើរជាដើម។ នៅថ្នាក់ក្រោមជាតិ ចំនុចមួយចំនួនដែលមានចែងនៅក្នុងច្បាប់ពុំអាចអនុវត្តបានដោយសារ ការផ្សព្វផ្សាយអំពីច្បាប់ចរាចរណ៍ពុំទាន់ពេញលេញ និងជ្រួតជ្រាបជាពិសេសដល់ប្រជាជនរស់នៅតាមជនបទ ឯកសារច្បាប់ចរាចរណ៍ផ្លូវគោកថ្មីពុំមានគ្រប់គ្រាន់សូម្បីអាជ្ញាធរមូលដ្ឋាន កម្រិតយល់ដឹងនិងស្ថានភាពជីវភាពរបស់ប្រជាជននៅមានកម្រិតដូចជាក្រុមគ្រួសារក្រីក្រដែលមានកូនតូចច្រើននិងមានម៉ូតូ១គ្រឿងជាមធ្យោបាយធ្វើដំណើរ ការប្រើប្រាស់រថយន្តដឹកទំនិញមកដឹកកម្មកររោងចក្រ អាជីវកម្មលក់ស្រាបៀរច្រើនហួសប្រម៉ាណ និងពុំមានស្លាកសញ្ញានិងភ្លើងសញ្ញាគ្រប់គ្រាន់នៅតាមមូលដ្ឋាន។

